**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.....០៧០......បទ.អ.ប.ទ..៧៥

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រកាស

**ស្តីពីការ ដកហូត** *International Access Code* (IAC) **និង** *International Signaling Point Code* (ISPC)

~~~~~~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ ស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យ លេខ ០៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧ ស្តីពី ប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ-បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្របក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យ លេខ ០៥ អនក្របក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋាន រដ្ឋបាល និងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពីការរក្សាមាត់ច្រកទូរគមនាគមន៍អន្តរជាតិ "Basic International Gateway" ឱ្យមានតែ២ (ពីរ) ជាផ្លូវការគឺ (០០១ និង ០០៧) ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៧

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

ទូរស័ព្ទ : (៨៥៥) ២៣-៧២៤៨០៩/៤២៦៥១០

ទូរសារ : (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១/៤២៦៥៤១
~~~~~~~~~~~~~~~~~

-យោងអាជ្ញាប័ណ្ណផ្តល់សេវាទូរស័ព្ទសំឡេងតាមប្រព័ន្ធអ៊ិនធើណិត Voice over Internet Protocol (VoIP) ដែលផ្តល់ឱ្យដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

## ស ម្រេ ច

**ប្រការ ១ :** ដកហូត ***International Access Code*** (IAC) និង ***International Signaling Point Code*** (ISPC) ពីបណ្តាលក្រុមហ៊ុនដែលផ្តល់សេវាទូរស័ព្ទសំឡេងតាមប្រព័ន្ធអ៊ិនធើណិត **(VoIP)** ជាស្ថាពរ ។

**ប្រការ ២ :** តាមបច្ចេកវិទ្យាសេវាទូរស័ព្ទសំឡេងតាមប្រព័ន្ធអ៊ិនធើណិត **(VoIP)** មិនចាំបាច់មាន ***International Access Code*** (IAC) និង ***International Signaling Point Code*** (ISPC) ទេ ដូច្នេះ ក្រសួងនឹងផ្តល់លេខសំគាល់ Prefix Codes ដែលមានបីលេខ (XXX) ជូនក្រុមហ៊ុនដែលផ្តល់សេវាទូរស័ព្ទសំឡេងតាមប្រព័ន្ធអ៊ិនធើណិតជំនួសវិញ ។

**ប្រការ ៣ :** គ្រប់ប្រតិបត្តិករទាំងអស់ត្រូវអនុវត្តតាមលិខិតលេខ ៦០០ ប.ទ.អ.ប.ទ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការភ្ជាប់បណ្តាញជាមួយទូរគមនាគមន៍កម្ពុជា (***Telecom Cambodia***-TC) ឱ្យមានប្រសិទ្ធិភាព ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អធិការដ្ឋាន និងក្រុមហ៊ុនដែលផ្តល់សេវាទូរស័ព្ទសំឡេងតាមប្រព័ន្ធអ៊ិនធើណិត **(VoIP)** ទាំងអស់ត្រូវទទួលខុសត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៧**

**រ ដ្ឋ ម ន្ត្រី**

**សូ-ឃុន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
"ដើម្បីជូនជ្រាបជាខ្ពង់ខ្ពស់"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :...៦០០........បទ.អ.ប.ទ.........

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

**ជំរាបមក**

**លោកឧកញ៉ា លោក លោកស្រី ប្រធានក្រុមហ៊ុនអាជីវកម្មផ្តល់សេវាទូរគមនាគមន៍**

**កម្មវត្ថុ:** ស្តីពីការភ្ជាប់បណ្តាញជាមួយទូរគមនាគមន៍កម្ពុជា (Telecom Cambodia-TC)

**យោង :** - អាជ្ញាប័ណ្ណផ្តល់សេវាអ៊ិនធឺណែត (ISP License) , សេវាទូរស័ព្ទសំលេងតាមប្រព័ន្ធអ៊ិនធឺណែត (VoIP License) , ទូរស័ព្ទចល័ត (Mobile License) , ទូរស័ព្ទខ្សែ (Fixed Phone) , ទូរស័ព្ទឥតខ្សែ (WLL) , ... ។

- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចនាយករដ្ឋមន្ត្រី** នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងចំណូល និង សន្តិសុខជាតិលើវិស័យទូរគមនាគមន៍ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានកិត្តិយសសូមជំរាបមក **លោកឧកញ៉ា លោក លោកស្រី** ប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់អោយបានជ្រាបថា : គោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ច្បាស់លាស់អោយគ្រប់ប្រតិបត្តិករដែលប្រកបអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ទាំងអស់ត្រូវតែភ្ជាប់បណ្តាញឆ្លងកាត់ទាំងក្នុងប្រទេស និង ក្រៅប្រទេសតាមចំណុចរួមនៃមជ្ឈមណ្ឌលកណ្តាលរបស់ទូរគមនាគមន៍កម្ពុជា (Telecom Cambodia-TC) ។

កន្លងមកមានប្រតិបត្តិករខ្លះបានធ្វើការតភ្ជាប់បណ្តាញផ្ទាល់ (Direct Connection) ពីប្រព័ន្ធរបស់ខ្លួនទៅប្រតិបត្តិករមួយទៀត ទាំងក្នុងប្រទេស និង ក្រៅប្រទេសដោយពុំបានឆ្លងកាត់ទូរគមនាគមន៍កម្ពុជាទេ ។

ដូច្នេះចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សូមប្រតិបត្តិករទាំងអស់ដែលប្រកបអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ មកទំនាក់ទំនងភ្ជាប់បណ្តាញជាមួយទូរគមនាគមន៍កម្ពុជា (TC) អោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និង កាត់ផ្តាច់ជាបន្ទាន់រាល់ការភ្ជាប់បណ្តាញផ្ទាល់ទាំងក្នុង និង ក្រៅប្រទេសរបស់ខ្លួនកន្លងមក ។

ក្នុងករណីមិនគោរពតាមការណែនាំខាងលើនេះ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍នឹងអនុវត្តន៍តាមវិធានការណ៍ជាក់ស្តែងកាត់ផ្តាច់បណ្តាញបណ្តោះអាសន្ន និង អាចឈានដល់ការដកហូតអាជ្ញាប័ណ្ណបញ្ឈប់ការធ្វើអាជីវកម្មជាស្ថាពរ ។

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ : (៨៥៥) ២៣-៧២៤៨០៩/៤២៦៥១០
ទូរសារ : (៨៥៥) ២៣.៤២៦៩៩២/៤២៦០១៧/៤២៦៥៤១

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្នុងនាមអាណាព្យាបាលបច្ចេកទេសនឹងចូលរួមសហការជួយអន្តរាគមន៍នូវរាល់បាតុភាពមិនប្រក្រតីណាមួយក្នុងការភ្ជាប់បណ្តាញនេះ ។

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សង្ឃឹមយ៉ាងមុតមាំថា **លោកឧកញ៉ា លោក លោកស្រី** ប្រធានក្រុមហ៊ុនទាំងអស់នឹងអនុវត្តន៍តាមការណែនាំនេះអោយមានប្រសិទ្ធិភាពខ្ពស់ជាក់ជាពុំខាន ។

*សូម លោកឧកញ៉ា លោក លោកស្រី ទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។*

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០៧

**រដ្ឋមន្ត្រី**

**សូ-ឃុន**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទការល័យ សម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
- ឯកឧត្តម លោកឧកញ៉ា លោក ប្រធាន អនុប្រធាន និង សមាជិក ក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

"**ដើម្បីជូនជ្រាប**"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :......១៦៧..........បទ..ប្រក..

[illegible]

# ប្រកាស

## ស្តីពី

## អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០២ ស្តីពីការកែសំរួល និង បំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និង បណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។
- យោងតាមសំណើរបស់នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័តនិងទំនាក់ទំនងអន្តរជាតិ។
- តាមសេចក្តីសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥។

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០, ៤២៦៥១០

ទូរសារ: (៨៥៥ ២៣-៤២៦៩៥២ ៤២៦០១១

# សំរេច

ប្រការ ១ :-

ប្រកាសនេះមានគោលដៅគ្រប់គ្រង និងផ្តល់អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់ ។

ប្រការ ២ :-

- អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ គឺជាអាជ្ញាប័ណ្ណដែលត្រូវផ្តល់ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្ម បំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ បន្ថែមលើសេវាប្រៃសណីយ៍ដែលស្ថិតក្រោមអាជីវកម្ម របស់រដ្ឋ ដើម្បី ជួយបំពេញ និងទ្រទ្រង់សេវាប្រៃសណីយ៍ និងបំរើតាមសំណូមពររបស់ប្រជាពលរដ្ឋ ។
- សេវាបញ្ញើឆាប់រហ័សអន្តរជាតិ គឺជាសេវាកម្មប្រៃសណីយ៍ទំនើបមួយដែលបានរៀបចំប្រព័ន្ធសេវាមាន លក្ខណៈអន្តរជាតិ ។ សេវានេះត្រូវបានធានានូវសុវត្ថិភាពចាប់តាំងពី ទទួល បញ្ជូន និងចែកដល់ដៃ អ្នកទទួល មានការតាមដានជាប្រចាំ ដោយការកត់ត្រាតាមប្រព័ន្ធព័ត៌មានវិទ្យា និងមានអទិភាពជាង បញ្ញើដទៃទៀត ។

ប្រការ ៣ :-

គ្មានផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ណាមួយអាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ មានសុពលភាពដែលចេញដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ឡើយ ។

ប្រការ ៤ :-

ផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ដែលអាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិបាន ត្រូវមានលក្ខ័ខ័ណ្ឌ ដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ឬបរទេស
- មានកាយសម្បទារគ្រប់គ្រាន់
- មានបទពិសោធន៏ខាងវិស័យប្រៃសណីយ៍
- បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។
- មានទីតាំងសមស្រប និង ច្បាស់លាស់ ត្រូវមានឯកសារបញ្ជាក់ ។

ប្រការ ៥ :-

ផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងចង់ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ត្រូវដាក់ពាក្យសុំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ នៅនាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រការ ៦ :-

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីសេចក្តីសំរេចរបស់ក្រសួង ចំពោះការអនុញ្ញាត ឬមិនអនុញ្ញាត ពាក្យសុំក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ ។

ប្រការ ៧ :-

អ្នកកាន់អាជ្ញាប័ណ្ណ មិនអាច ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ទៅឱ្យអ្នកផ្សេងទៀតបានឡើយ ។ ការបោះបង់ ឬការផ្ទេរ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ទៅឱ្យជនណាផ្សេងទៀត អាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រការ ៨ :-

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសិទ្ធិក្នុងការ កែសំរួល ព្យួរ និង បដិសេធន៍ ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណីដូចខាងក្រោម:

ក- ការកែសំរួល អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណបានស្នើសុំ :
- ពង្រីកសាខាបន្ថែម
- ប្តូរទីតាំង
- លុបចោលសាខាមួយចំនួន ។

ខ- ការព្យួរអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណ :
- ធ្វើអាជីវកម្មប្រៃសណីយ៍ខុសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ
- ពុំបានបង់ប្រាក់វិភាគទាន ជូននាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ តាមកាលកំណត់ ។
- មិនបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួនបីលើក ក្នុងមួយលើកមានរយៈពេល ១៥ថ្ងៃ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍នេះ នឹងត្រូវព្យួររហូតដល់អស់សុពលភាព ។
- ត្រូវបានស្ថាប័នមានសមត្ថកិច្ចស្នើសុំអោយព្យួរ ដោយមូលហេតុមានការរំលោភលើច្បាប់ជា ធរមាន ។

គ- ការបដិសេធន៍ ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណី :
- អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ អស់សុពលភាពហើយពុំបានស្នើសុំបន្ត
- អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ត្រូវបានព្យួរ ២ដង ហើយពុំរាងចាល
- អ្នកកាន់អាជ្ញាប័ណ្ណបាន ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ទៅអោយអ្នកផ្សេងទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- អ្នកកាន់អាជ្ញាប័ណ្ណពុំបានធ្វើសកម្មភាពរយៈពេល ៦ខែ ក្រោយពីទទួលបានអាជ្ញាប័ណ្ណ ។

ប្រការ ៩ :-

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ ជាលាយលក្ខណ៍អក្សរ និងចុះផ្សាយតាមបណ្តាញព័ត៌មាន នូវសេចក្តីសំរេចរបស់ក្រសួង ចំពោះការបដិសេធន៍ ឬ ដកហូតមកវិញនូវអាជ្ញាប័ណ្ណ អាជីវកម្មប្រៃសណីយ៍។ អ្នកកាន់អាជ្ញាប័ណ្ណ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹង តាមបញ្ញើអនុសិដ្ឋ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ប្រការ ១០ :-

អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេលតិចបំផុត២ឆ្នាំ និងច្រើនបំផុត៥ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ ក្នុងករណីបន្តធ្វើអាជីវកម្ម អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ឱ្យបាន ៣០ថ្ងៃ មុនពេលអាជ្ញាប័ណ្ណ អស់សុពលភាព។

ប្រការ ១១ :-

តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ គណនាតាមសុពលភាពនៃអាជ្ញាប័ណ្ណនីមួយៗ ហើយអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណ អាជីវកម្មប្រៃសណីយ៍ ត្រូវបង់ជាប្រាក់ដុល្លារអាមេរិក ឬជាប្រាក់រៀលទៅតាមអត្រាប្តូរប្រាក់របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា តាមប្រភេទដូចតទៅ :

ក. តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល២ឆ្នាំ ត្រូវបានកំណត់ ៥.០០០ដុល្លារអាមេរិក :
- ត្រូវបង់ ៥០០ ដុល្លារអាមេរិក នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ៤.៥០០ ដុល្លារអាមេរិក នៅពេលទទួលបានគោលការណ៍អនុញ្ញាតពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ខ. តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៣ឆ្នាំ ត្រូវបានកំណត់ ៧.០៣០ដុល្លារ អាមេរិក ។
- ត្រូវបង់ ៥០០ ដុល្លារអាមេរិក នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ៦.៥៣០ ដុល្លារអាមេរិក នៅពេលទទួលបានគោលការណ៍អនុញ្ញាតពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

គ. តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៤ឆ្នាំ ត្រូវបានកំណត់ ៨.៨៦០ដុល្លារ អាមេរិក ។
- ត្រូវបង់ ៥០០ ដុល្លារអាមេរិក នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ៨.៣៦០ ដុល្លារអាមេរិក នៅពេលទទួលបានគោលការណ៍អនុញ្ញាតពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ឃ. តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៥ឆ្នាំ ត្រូវបានកំណត់ ១០.៥០០ដុល្លារអាមេរិក។

- ត្រូវបង់ ៥០០ ដុល្លារអាមេរិក នៅពេលដាក់ពាក្យសុំដំបូង។
- ត្រូវបង់ ១០.០០០ ដុល្លារអាមេរិក នៅពេលទទួលបានគោលការណ៍អនុញ្ញាតពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ក្នុងករណីពាក្យស្នើសុំអាជ្ញាប័ណ្ណ ពុំទទួលបានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់បង់ ដំបូងចំនួន ៥០០ដុល្លារអាមេរិកត្រូវប្រគល់ជូនអ្នកស្នើសុំវិញ។

ក្នុងករណីអ្នកដាក់ពាក្យ បោះបង់ចោលការស្នើសុំអាជ្ញាប័ណ្ណក្រោយពេលគោលការណ៍ត្រូវបានអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់បង់ដំបូងចំនួន ៥០០ដុល្លារអាមេរិក នេះត្រូវទុក ជាប្រយោជន៍របស់ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍។

ប្រការ ១២ :-

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិក្នុងកំរិតជាក់លាក់ និង ត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍នោះតែប៉ុណ្ណោះ។ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណ ចង់ពង្រីកសាខាបន្ថែម ឬប្តូរទីតាំង ឬសុំលុបចោលសាខាមួយចំនួនដែលមានចែងក្នុងអាជ្ញាប័ណ្ណ ត្រូវសុំការ អនុញ្ញាតជាមុន ពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។

ប្រការ ១៣ :-

អ្នកកាន់អាជ្ញាប័ណ្ណអាចបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដែលមានទម្ងន់ក្រោម៥០០ក្រាមបានករណីអ្នកកាន់អាជ្ញាប័ណ្ណនោះគិតតម្លៃសេវាផ្ញើ លើស៥ដង នៃតម្លៃសេវាផ្ញើលិខិតធម្មតារបស់រដ្ឋ។

ប្រការ ១៤ :-

អ្នកកាន់អាជ្ញាប័ណ្ណអាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិគ្រប់ប្រភេទ លើកលែងតែវត្ថុដែលត្រូវហាមឃាត់ ដូចមានចែងក្នុងច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ត្រង់មាត្រា១៩ ។

ប្រការ ១៥ :-

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុ (Financial Statement) ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀងរាល់ត្រីមាសអោយបានទៀងទាត់។ របាយការណ៍នេះត្រូវបានរក្សាការសំងាត់។

ប្រការ ១៦ :-

អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវ និង សងចំពោះអ្នកផ្ញើ ឬអ្នកទទួល ក្នុងករណីមានការបាត់បង់ ឬខូចខាតនូវរាល់បញ្ញើឆាប់រហ័សអន្តរជាតិ លើកលែងបញ្ញើត្រូវបានបាត់បង់ ឬខូចខាត ដោយករណីប្រធានស័ក្តិ ឬបញ្ញើដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ត្រូវបានរឹបអូស។

**ប្រការ ១៧ :-**

អ្នកផ្ញើ ឬអ្នកទទួល មានសិទ្ធិប្តឹងតវ៉ាអំពីបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានបាត់បង់ ឬខូចខាត ចំពោះអ្នកកាន់អាជ្ញាប័ណ្ណ ដែលខ្លួនបានផ្ញើ ឬទទួល ក្នុងកំឡុងពេល ០៦ខែ គិតចាប់ពីថ្ងៃផ្ញើ ឬថ្ងៃទទួលបញ្ញើ។

**ប្រការ ១៨ :-**

នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានភារកិច្ចគ្រប់គ្រងអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ និងតាមដានទូរវាល់សកម្មភាពរបស់ក្រុមហ៊ុនធ្វើអាជីវកម្ម បំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ អោយអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ដែលបានផ្តល់ជូន។

**ប្រការ ១៩ :-**

នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនឯកជនធ្វើអាជីវកម្មសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដើម្បីកសាងសំណុំឯកសារនៅពេលមានវិវាទ ឬការតវ៉ាផ្សេងៗ។

**ប្រការ ២០ :-**

រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២១ :-**

អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ អធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥

រដ្ឋមន្ត្រី

សូ-ខុន

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម

  "ដើម្បីជូនជ្រាប"
- ដូចប្រការ២១ "ដើម្បីអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ